# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថា
## ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨»

ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

ក្រសួងបរិស្ថាន ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលជាទីរាប់អាន!*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក សមាជិកានៃអង្គសន្និបាតទាំងមូលជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ក្នុងពិធីបើក **«សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨»** ដែលជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់មួយ សម្រាប់វិស័យបរិស្ថាន និងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតពេលដ៏មមាញឹកអញ្ជើញចូលរួមក្នុងពិធីនេះ ដែលញ៉ាំងឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តទៅដោយភាពអធិកអធម ក្នុងបរិយាកាសរីករាយ។

ជាមួយគ្នានេះដែរ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន ដែលបានខិតខំយកអស់កម្លាំងកាយ ចិត្ត បញ្ញា និងស្មារតីក្នុងការបំពេញតួនាទី ភារកិច្ច និងបេសកកម្មរបស់ខ្លួន ដើម្បីបុព្វហេតុកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព សំដៅជានាឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាជនយើង។

ដូចឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានបញ្ជាក់ជូនអម្បាញមិញហើយថា ការជួបជុំគ្នាថ្ងៃនេះមិនត្រឹមតែជាសក្ខីភាពបញ្ជាក់នូវការចូលរួមអបអរសាទរចំពោះសមិទ្ធផលនានា ដែលក្រសួង និងក្រុមប្រឹក្សាជាតិសម្រេចបានក្នុងឆ្នាំ២០១៧ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាសសម្រាប់យើងទាំងអស់គ្នាចូលរួមពិនិត្យវាយតម្លៃវឌ្ឍនភាពការងារ ដែលសម្រេចបានក្នុងអំឡុងពេល៤ឆ្នាំ គិតចាប់តាំងពីដើមអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា។

ក្នុងនាម**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមចូលរួមអបអរសាទរចំពោះសមិទ្ធផលសំខាន់ៗជាច្រើន ដែលក្រសួង និង ក្រុមប្រឹក្សាជាតិសម្រេចបានរហូតមកដល់ពេលនេះ ហើយខ្ញុំក៏សូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការគាំទ្រ និងលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃស្ថាប័នទាំងពីរបន្តខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានកាន់តែខ្លាំងក្លាថែមទៀត ដើម្បីឆ្លើយតបទៅនឹងបំណងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមទំនើបមួយ ដែលមានបរិស្ថានល្អស្អាត និងការរស់នៅដោយចីរភាព សម្រាប់ប្រជាជនគ្រប់ៗរូប និងគ្រប់ៗជំនាន់។

ខ្ញុំសង្ឃឹមថា សន្និបាតរយៈពេលបីថ្ងៃនេះ នឹងផ្តល់ឱកាសគ្រប់គ្រាន់ដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃស្ថាប័នទាំងពីរ និងអ្នកពាក់ព័ន្ធបានពិនិត្យ ពិភាក្សា និងវាយតម្លៃលើលទ្ធផលការងារ និងស្វែងរកជម្រើសដ៏ប្រសើរក្នុងការកំណត់ទិសដៅការងារ និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៨ ក៏ដូចជាឆ្នាំបន្តបន្ទាប់ទៀត។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!*

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ការងារបរិស្ថានជាកិច្ចការសកល និងមានលក្ខណៈអន្តរវិស័យ ដែលត្រូវបានពិភពលោកយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងពេលបច្ចុប្បន្ននេះ ហើយក៏ជាកិច្ចការដែលទាមទារឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងពិភពលោក ក្នុងការរួមគ្នាថែរក្សា ការពារ និងស្វែងរកវិធានការដោះស្រាយបញ្ហាប្រឈម ដើម្បីធានាឱ្យបាននូវគុណភាពបរិស្ថាន តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី ការរស់នៅដោយចីរភាព និងសុវត្ថិភាពនៃភពផែនដី។

ក្នុងក្របខណ្ឌជាតិ ការងារបរិស្ថានទាមទារឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ស្របតាមគោលដៅអភិវឌ្ឍន៍ដោយចីរភាព។ នៅចំពោះមុខកិច្ចការដ៏ចម្បងនេះ រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវជំហរវិជ្ជមាន ក្នុងការពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដោយបានជំរុញឱ្យក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បន្តចូលរួមអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាយន្តការសម្របសម្រួលការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់បច្ចេកវិទ្យាបៃតង និងការអភិវឌ្ឍដោយចីរភាព។ល។

ជាមួយគ្នានេះ ក្រសួងបរិស្ថានបាននិងកំពុងដើរតួយ៉ាងសំខាន់ក្នុងនាមជាស្ថាប័ននិយតករ ក្នុងការរៀបចំ និងផ្តួចផ្តើមឱ្យមានការធ្វើកំណែទម្រង់សំខាន់ៗនៅក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ក៏ដូចជាជំរុញឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ទាំងនេះឱ្យមានប្រសិទ្ធភាព ដើម្បីធានារក្សាឱ្យបាននូវតុល្យភាពរវាងការអភិរក្សនិងការអភិវឌ្ឍ។ តាមរបាយការណ៍ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានបង្ហាញឱ្យឃើញថា សម្រាប់រយៈពេលជាង៤ឆ្នាំកន្លងមកនេះ ដោយមានកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើទំនើបកម្មស្ថាប័ន ស្ថាប័នទាំងពីរ

សម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់នូវកំណែទម្រង់ស្ថាប័ន គោលនយោបាយនិងច្បាប់ ការអនុវត្តថវិកាកម្មវិធី ការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការ ការគ្រប់គ្រងធនធានមនុស្សនិងកិច្ចគាំពារសុខុមាលភាពមន្ត្រីរាជការ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្គត់ផ្គង់មធ្យោបាយ និងសម្ភារៈ ដែលជាមូលដ្ឋានគ្រឹះសម្រាប់លើកកម្ពស់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។ ទន្ទឹមនឹងនេះ ឯកឧត្តមរដ្ឋមន្ត្រីក៏បានរំលេចឱ្យឃើញនូវភាពចាំបាច់ក្នុងការពិនិត្យ ពិភាក្សា និងរួមគ្នាស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនានា ដើម្បីជាត្រីវិស័យតម្រង់ទិស សម្រាប់ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ សមិទ្ធផលទាំងនេះ គឺពិតជាមិនអាចកាត់ផ្តាច់ចេញពីការចូលរួមសហការ និងការគាំទ្រពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពជុំវិញខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រជាសហគមន៍មូលដ្ឋាននោះឡើយ។

ការធ្វើទំនើបកម្មស្ថាប័ន គឺជាកិច្ចការដែលគ្រប់ក្រសួង ស្ថាប័នត្រូវបន្តធ្វើ និងធ្វើជាប់ជាប្រចាំ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងភាពប្រសើរឡើងនៃការផ្តល់សេវាសាធារណៈ សំដៅឆ្លើយតបទៅនឹងដំណើរវិវឌ្ឍន៍នៃសង្គមជាតិ។

ជារួម ខ្ញុំអាចវាយតម្លៃបានថា ការធ្វើទំនើបកម្មស្ថាប័ននៅក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិពិតជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ជាពិសេសប្រសិទ្ធភាពគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ។ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រសួង និងក្រុមប្រឹក្សាជាតិ នឹងបន្តស្មារតីខិតខំប្រឹងប្រែងក្នុងការដឹកនាំ និងសម្របសម្រួលការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ទាំងកម្រិតគោលនយោបាយ និងបច្ចេកទេស។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!***

ស្របពេលដែលប្រទេសជាតិមានសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ កំណើនប្រជាជននៅតាមទីប្រជុំជន និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក៏មានការកើនឡើងយ៉ាងឆាប់រហ័ស ដែលបាននាំមកនូវបញ្ហាប្រឈមជាច្រើន និងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់គុណភាពបរិស្ថាន ធនធានធម្មជាតិ តុល្យភាពប្រព័ន្ធអេកូឡូស៊ី សោភ័ណភាពទីក្រុង និងសុខមាលភាពសង្គម។ បណ្តាទីប្រជុំជនក្រុងធំៗបាននិងកំពុងប្រឈមនឹងការកើនឡើងនូវបរិមាណសំណល់រឹង រាវ ការថយចុះគុណភាពទឹក ដី និងខ្យល់ ការរំខានដោយសម្លេង បញ្ហាកកស្ទះចរាចរណ៍ កំណើនតម្រូវការថាមពល ក៏ដូចជា កង្វះលំហបៃតង ដែលតម្រូវឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវពិចារណាស្វែងរកដំណោះស្រាយឱ្យបានសមស្រប។ ទន្ទឹមនឹងនេះ បញ្ហានៃការប្រែប្រួលអាកាសធាតុក៏បានរួមចំណែកជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីផងដែរ ដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តសហការឱ្យបានជិតស្និទ្ធ ក្នុងការស្វែងរកវិធានការដោះស្រាយ។

ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូលមេត្តាយកចិត្តទុកដាក់ស្តាប់នូវបទបង្ហាញស្តីពីវឌ្ឍនភាពការងារ បញ្ហាប្រឈមចំពោះមុខ និងសំណូមពរ ដើម្បីរួមគ្នាស្វែងរកវិធានការ

សមស្រប និងកំណត់ទិសដៅការងារ សំដៅឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិនៅកម្ពុជា។ ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យអង្គសន្និបាតពិនិត្យ ពិភាក្សា និងស្វែងរកដំណោះស្រាយលើបញ្ហាប្រឈម និងតម្រូវការចាំបាច់នានា ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

**១. សម្រាប់ការងាររដ្ឋបាលនិងហិរញ្ញវត្ថុ និងការធ្វើទំនើបកម្មស្ថាប័ន**

- ក្រសួងបរិស្ថានត្រូវបន្តធ្វើទំនើបកម្មស្ថាប័ន និងធ្វើជាប់ជាប្រចាំ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ការកសាងទំនុកចិត្ត និងភាពប្រសើរឡើងនៃការផ្តល់សេវាសាធារណៈ សំដៅឆ្លើយតបទៅនឹងដំណើរវិវត្តន៍ និងតម្រូវការជាក់ស្តែងរបស់សង្គមជាតិ។
- ក្រសួងបរិស្ថានត្រូវបន្តលើកកម្ពស់ និងជំរុញការអនុវត្តឱ្យបានទូលំទូលាយនូវគោលនយោបាយគាំពារមន្ត្រីរាជការ ដោយផ្អែកលើលទ្ធភាពជាក់ស្តែង។
- ក្រសួងបរិស្ថានត្រូវបន្តការកែលម្អការរៀបចំផែនការថវិកា និងការគ្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីឱ្យបានហ្មត់ចត់។
- ក្រសួងបរិស្ថានត្រូវបន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងជំរុញការអនុវត្តមុខងារ ដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន អប់រំផ្សព្វផ្សាយបរិស្ថាន ការគ្រប់គ្រងតំបន់ការពារធម្មជាតិនិងសហគមន៍តំបន់ការពារធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។
- ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការអនុវត្ត «យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣» ឱ្យមានប្រសិទ្ធភាពខ្ពស់ បន្ទាប់ពីរាជរដ្ឋាភិបាលអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។
- ក្រសួងបរិស្ថានត្រូវបន្តសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការពន្លឿនការបញ្ចប់សេចក្តីព្រាង **«ក្រមបរិស្ថាន និងធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា»** ដែលជាលិខិតូបករណ៍គតិយុត្ត និងជាឯកសារតម្រង់ទិសដ៏សំខាន់ សម្រាប់ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ។

**២. សម្រាប់ការងារគាំពារបរិស្ថាន**

- ក្រសួងត្រូវដឹកនាំសម្របសម្រួលការរៀបចំនិងអនុវត្តផែនការសកម្មភាព និងការស្វែងរកកញ្ចប់ថវិកាសម្រាប់វិនិយោគលើគម្រោងស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់ និងពិនិត្យលទ្ធភាពបង្កើនថវិកានៃកញ្ចប់សេវាអនាម័យបរិស្ថាន សម្រាប់ពង្រីកវិសាលភាពការងារគ្រប់គ្រងសំណល់ទីប្រជុំជន ជាពិសេសសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុវត្តអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ឱ្យកាន់តែមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។
- ក្រសួងបរិស្ថានត្រូវបន្តជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីទប់ស្កាត់ កាត់បន្ថយ និងស្តារការបំពុលបរិស្ថានពីសកម្មភាពអភិវឌ្ឍន៍នានា ជាអាទិ៍ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងកិច្ចសន្យាការពារបរិស្ថាន ការចុះត្រួតពិនិត្យជាប្រចាំតាមប្រភពបំពុល និងការដោះស្រាយរាល់បណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន។

- ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំបង្កើតយន្តការត្រួតពិនិត្យការគ្រប់គ្រង និងការបញ្ចេញសំណល់ពីតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម ដើម្បីទប់ស្កាត់ការបំពុលបរិស្ថាន និងធានាការអភិវឌ្ឍដោយចីរភាព។
- ក្រសួងបរិស្ថាន ត្រូវបន្តនិងបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងវិស័យឯកជន ក្នុងការគៀរគធនធានសម្រាប់គាំពារបរិស្ថាន និងការការពារសុខភាពសាធារណៈ។

**៣. សម្រាប់ការងារការពារ និងអភិរក្សធនធានធម្មជាតិ**

- ក្រសួងបរិស្ថានត្រូវបន្តពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ តាមរយៈការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានាបន្ថែមទៀត។
- ក្រសួងបរិស្ថានត្រូវបន្តពង្រឹងការអនុវត្តការផ្ទេរមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ក្រសួងបរិស្ថានត្រូវជំរុញការសិក្សាកំណត់តំបន់គ្រប់គ្រង បោះបង្គោលព្រំតំបន់ការពារធម្មជាតិ និងរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ កាត់បន្ថយការទន្ទ្រានកាន់កាប់ដីព្រៃដោយខុសច្បាប់ កាត់បន្ថយទំនាស់នៃការប្រើប្រាស់ដីព្រៃ និងទប់ស្កាត់បទល្មើសធនធានធម្មជាតិ។
- ក្រសួងបរិស្ថានត្រូវសិក្សាអំពីសក្តានុពលធនធានធម្មជាតិ ជីវៈចម្រុះ វប្បធម៌ និងប្រវត្តិសាស្ត្រ ដើម្បីរៀបចំបង្កើតតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិបន្ថែមទៀត។
- ក្រសួងបរិស្ថានត្រូវបន្តពង្រឹងសមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិ និងជំរុញការសិក្សាកំណត់សក្តានុពលសហគមន៍នីមួយៗ ដើម្បីជួយដល់សហគមន៍ក្នុងការបង្កើតមុខរបរថ្មី ការអភិវឌ្ឍកសិកម្ម និងការផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ សំដៅលើកស្ទួយជីវភាពសហគមន៍ ក៏ដូចជាការចូលរួមរបស់ពួកគាត់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។
- ក្រសួងបរិស្ថានត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកៀរគរធនធានថវិកា និងបច្ចេកទេស សម្រាប់គាំទ្រដល់ការអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងការពារ និងអភិរក្សធនធានធម្មជាតិ ពិសេសការអនុវត្តគម្រោងរេដបូក និងគម្រោងជួយដល់សហគមន៍មូលដ្ឋាននៅក្នុងតំបន់ការពារធម្មជាតិ។

**៤. សម្រាប់ការងារអភិវឌ្ឍន៍ដោយចីរភាព**

- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបន្តសម្របសម្រួល និងសហការជាមួយគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅធានាបានតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ។
- ក្រុមប្រឹក្សាជាតិត្រូវជំរុញការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីជាមូលដ្ឋានតម្រង់ទិសការរៀបចំ ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍដោយចីរភាព ជាពិសេសការរៀបចំ និងអនុវត្ត «ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព»។

- ក្រុមប្រឹក្សាជាតិត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាអំពីលទ្ធភាពនៃការពង្រីកការប្រើប្រាស់ថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យសម្រាប់ផលិតអគ្គិសនី។
- ក្រុមប្រឹក្សាជាតិត្រូវសិក្សារៀបចំគោលនយោបាយ «ការទូទាត់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី» និង «កម្រៃលើការបំពុល» ដោយផ្អែកលើបទពិសោធនៃការអនុវត្តគម្រោងសាកល្បងប្រភេទនេះ។
- ក្រុមប្រឹក្សាជាតិត្រូវបន្តសម្របសម្រួល និងសហការជាមួយគ្រប់ភាគី ក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងជីវសុវត្ថិភាព និងការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាបៃតង។
- ក្រុមប្រឹក្សាជាតិត្រូវបន្តសម្របសម្រួលនិងសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងការបញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតង និងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគ និងអភិវឌ្ឍន៍ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា របាយការណ៍ស្តីពីការចូលរួមរបស់កម្ពុជា ក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។

**៥. សម្រាប់ការងារអប់រំផ្សព្វផ្សាយបរិស្ថាន**

- ក្រសួងបរិស្ថានត្រូវបង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថាន សំដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបរិស្ថានតាមគ្រប់មធ្យោបាយនិងរូបភាព ដើម្បីកែប្រែទាំងផ្នត់គំនិត និងឥរិយាបថរបស់ប្រជាពលរដ្ឋឱ្យស្រឡាញ់បរិស្ថាន និងមានស្មារតីចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព។
- ក្រសួងបរិស្ថានត្រូវបន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូពាក់ព័ន្ធ ជាពិសេសជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងសកម្មភាព សិក្សា ស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ ពិគ្រោះយោបល់ និងបញ្ជ្រាបចំណេះដឹងស្តីពីបរិស្ថានឱ្យបានកាន់តែស៊ីជម្រៅនិងទូលំទូលាយ។
- ក្រសួងបរិស្ថានត្រូវបន្តរៀបចំបង្កើតប្រព័ន្ធទិន្នន័យបរិស្ថាន និងសេវាកម្មព័ត៌មានភូមិសាស្ត្រ ដើម្បីជាមូលដ្ឋានសម្រាប់ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ក៏ដូចជាសម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!***

ខ្ញុំមានជំនឿយ៉ាងមុតមាំថា តាមរយៈសន្និបាតរយៈពេលបីថ្ងៃនេះ យើងទាំងអស់គ្នានឹងទទួលបាននូវឱកាសយ៉ាងពេញលេញ ក្នុងការចូលរួមចែករំលែកចំណេះដឹង និងបទពិសោធ ក្នុងការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដែលជាកិច្ចការដ៏ចម្បងចំពោះមុខ និងតម្រូវឱ្យយើងទាំងអស់គ្នា បន្តចូលរួម

គ្រប់គ្រង និងដោះស្រាយបញ្ហាឱ្យបានកាន់តែប្រសើរថែមទៀត។ ខ្ញុំសូមស្នើឱ្យអង្គសន្និបាតទាំងមូល មេត្តាយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់បញ្ហាអាទិភាព ទិសដៅការងារ និងផែនការសកម្មភាព សម្រាប់ឆ្លើយតបតម្រូវការចំពោះមុខរបស់សង្គមជាតិ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ហើយខ្ញុំសង្ឃឹមថា មន្ត្រីយើងទាំងអស់គ្នានឹងបន្តអនុវត្តឱ្យបានជោគជ័យនូវរាល់ភារកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ជូន ដើម្បីឧត្តមប្រយោជន៍របស់ជាតិ មាតុភូមិ និងប្រជាជនកម្ពុជាគ្រប់ជំនាន់។

មុននឹងបញ្ចប់ ខ្ញុំសូមឱ្យក្រសួងបរិស្ថាន ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធបន្តនូវវប្បធម៌សហការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តផ្តល់នូវកិច្ចសហការនិងការគាំទ្រដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីឱ្យស្ថាប័នមួយនេះមានលទ្ធភាព ក្នុងការបញ្ជ្រាបការអភិវឌ្ឍដោយចីរភាព ទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងទិសដៅការងាររបស់ក្រសួងស្ថាប័នរៀងខ្លួន ពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវៈសុវត្ថិភាព។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិទាំងអស់ សូមប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តិទៅប្រកបដោយភាពជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កា។

ខ្ញុំសូមប្រកាសបើក «សន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨» ចាប់ពីពេលនេះតទៅ៕

**សូមអរគុណ**!